# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ១៤ អនក្រ.បក

## អនុក្រឹត្យ

## ស្តីពី

## ការកែសម្រួលអនុក្រឹត្យលេខ ៣៩ អនក្រ.បកចុះថ្ងៃទី ២៤ ខែ សីហា ឆ្នាំ ២០០៤ ស្តីពីការបង្កើតអាជ្ញាធរជាតិទេសចរណ៍កម្ពុជា

---

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យលេខ ៣៩អនក្រ.បក ចុះថ្ងៃទី ២៤ ខែ សីហា ឆ្នាំ២០០៤ ស្តីពីការបង្កើតអាជ្ញាធរជាតិទេសចរណ៍កម្ពុជា
- យោងតាមភាពចាំបាច់នៃការងារ

## សម្រេច

**មាត្រាមួយ:** ត្រូវបានកែសម្រួលមាត្រា២ និងមាត្រា៣នៃអនុក្រឹត្យលេខ ៣៩ អនក្រ.បកចុះថ្ងៃទី ២៤ ខែ សីហា ឆ្នាំ២០០៤ ស្តីពីការ បង្កើតអាជ្ញាធរជាតិទេសចរណ៍កម្ពុជាដូចតទៅ :

**មាត្រា២ថ្មី:** អាជ្ញាធរជាតិទេសចរណ៍កម្ពុជាមានសមាសភាពដូចតទៅ :

| | | |
|---|---|---|
| ១- ឯកឧត្តម ម៉េង ស៊ីរីវុឌ្ឍ | ទេសរដ្ឋមន្ត្រី | ប្រធាន |
| ២- អ្នកអង្គម្ចាស់ ស៊ីសុវត្ថិ ប៉័ណ្ណារ៉ា ស៊ីរីវុឌ្ឍ | រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | អនុប្រធាន |
| ៣- ឯកឧត្តម ឡាយ ប្រហស្ស | រដ្ឋមន្ត្រីក្រសួងទេសចរណ៍ | អនុប្រធាន |
| ៤- ឯកឧត្តម ថោង ខុន | រដ្ឋលេខាធិការក្រសួងទេសចរណ៍ | អនុប្រធាន |

| | | |
|---|---|---|
| ៥- ឯកឧត្តម **សេង លឹមនៅ** | រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី | អនុប្រធានប្រចាំការ |
| ៦- ឯកឧត្តម **ទូច ស៊ានតារ៉ាណា** | សមាជិក កសសស (OBSES) | អនុប្រធាន |
| ៧- ឯកឧត្តម **ទ្រាំ សុខា** | រដ្ឋលេខាធិការក្រសួងមហាផ្ទៃ | សមាជិក |
| ៨- ឯកឧត្តម **ឡុង វិសាលោ** | រដ្ឋលេខាធិការក្រសួងការបរទេស និងសហប្រតិបត្តិការអន្តជាតិ | សមាជិក |
| ៩- ឯកឧត្តម **គង់ វិបុល** | រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ១០- ឯកឧត្តម **ត្រាំ អ៊ីវតឹក** | រដ្ឋលេខាធិការក្រសួងសាធារណការ និងដឹកជញ្ជូន | សមាជិក |
| ១១- ឯកឧត្តម **ចំន្ទ តុងអ៊ីវ** | រដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិក |
| ១២- ឯកឧត្តម **ឆាន់ សារ៉ាន** | រដ្ឋលេខាធិការក្រសួងរៀបចំដែនដីនគរូបនីយកម្ម និង សំណង់ | សមាជិក |
| ១៣- ឯកឧត្តម **នឹម ថូត** | រដ្ឋលេខាធិការក្រសួងសង្គមកិច្ចអតីតយុទ្ធជន និងយុវនិតិសម្បទា | សមាជិក |
| ១៤- ឯកឧត្តម **ថាច់ ផែន** | រដ្ឋលេខាធិការក្រសួងពត៌មាន | សមាជិក |
| ១៥- ឯកឧត្តម **ពេជ្រ សោភ័ណ** | រដ្ឋលេខាធិការក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ | សមាជិក |
| ១៦- ឯកឧត្តម **ម៉ុន ណារិទ្ធ** | អគ្គនាយក អគ្គនាយកដ្ឋាននៃអាជ្ញាធរអប្សរា | សមាជិក |
| ១៧- ឯកឧត្តម **សូ ម៉ារ៉ា** | អគ្គលេខាធិការ "អជទក" និងជាអនុរដ្ឋលេខាធិការក្រសួងទេសចរណ៍ | សមាជិក |
| ១៨- ឯកឧត្តម **សយ សុខាន់** | អនុរដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល | សមាជិក |
| ១៩- លោក **យុន ឈុន្លី** | ប្រធាននាយកដ្ឋាននគរបាលទេសចរណ៍ នៃអគ្គស្នងការដ្ឋាននគរបាលជាតិ | សមាជិក |

**មាត្រា៣ថ្មី:** អាជ្ញាធរជាតិទេសចរណ៍កម្ពុជា ស្ថិតក្រោមការដឹកនាំ និងគ្រប់គ្រងរបស់ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ហើយមានតួនាទី និងភារកិច្ចដូចខាងក្រោម :

- ជួយរាជរដ្ឋាភិបាល ក្នុងការរៀបចំកសាងគោលនយោបាយ យុទ្ធសាស្ត្រជាតិ ផែនការអភិវឌ្ឍន៍ ការត្រួតពិនិត្យ និងសម្របសម្រួលការងារអនុវត្ត លើការអភិវឌ្ឍន៏វិស័យ ឧស្សាហកម្ម ទេសចរណ៍ជាតិ
- ត្រៀមការងារជូនរាជរដ្ឋាភិបាល ដើម្បីសម្រេចលើគម្រោងអភិវឌ្ឍន៍ ឬវិនិយោគនានា នៃ វិស័យឧស្សាហកម្ម ទេសចរណ៍
- ណែនាំក្រសួងទេសចរណ៍ ក្នុងការតាមដាន បញ្ជាក់ និងឆ្លុះបញ្ចាំងលទ្ធផល នៃការអនុវត្ត កម្មវិធីនយោបាយ យុទ្ធសាស្ត្រជាតិ ព្រមទាំងផែនការសកម្មភាពទាំងឡាយដែលទាក់ទងដល់ កិច្ចអភិវឌ្ឍន៏វិស័យឧស្សាហកម្ម ទេសចរណ៍
- កំណត់កិតអាទិភាព សំរាប់កិច្ចអភិវឌ្ឍន៏វិស័យឧស្សាហកម្មទេសចរណ៍
- ទទួលបន្ទុករៀបចំ និងលើកគម្រោងការងារ ផ្សព្វផ្សាយ ទីផ្សារទេសចរណ៍ រួមទាំង ព្រឹត្តិការណ៍ ទេសចរណ៍
- ទទួលបន្ទុករៀបចំ និងលើកគម្រោងការងារសន្តិសុខ និងសុវត្ថិភាពភ្ញៀវទេសចរណ៍

- សម្របសម្រួល និងទំនាក់ទំនងជាមួយក្រសួង ស្ថាប័ន ផ្នែកឯកជន និងសមាគមទាំងឡាយ ដែលប្រកបអាជីវកម្មវិស័យឧស្សាហកម្មទេសចរណ៍ លើការអនុវត្តកម្មវិធីនយោបាយ យុទ្ធសាស្ត្រជាតិ និងផែនការសកម្មភាព ដែលជាប់ទាក់ទងក្នុងការអភិវឌ្ឍវិស័យឧស្សាហកម្មទេសចរណ៍ ដោយឈរលើមូលដ្ឋាននៃផែនការ អភិវឌ្ឍន៍ជាតិ
- សហការជាមួយអគ្គនាយកដ្ឋាននៃអាជ្ញាធរអប្សរា ក្នុងការលើកគម្រោងអភិវឌ្ឍវិស័យ ទេសចរណ៍ នៅតំបន់សៀមរាប អង្គរ និង តំបន់ពាក់ព័ន្ធ ផ្សេងទៀត
- ទទួលខុសត្រូវក្នុងការអភិរក្ស និងអភិវឌ្ឍតំបន់ទេសចរណ៍សត្វផ្សោតទន្លេមេគង្គនៃខេត្តក្រចេះ និងខេត្តស្ទឹងត្រែង
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀត តាមការចាត់តាំងរបស់ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី
- ធ្វើរបាយការណ៍អំពីសកម្មភាពការងាររបស់ខ្លួនតាមកាលកំណត់អោយបានទៀងទាត់ ជូនប្រមុខ រាជរដ្ឋាភិបាល។

**មាត្រា៣** : បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារ ផ្ទុយពីអនុក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍។

**មាត្រា៤** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការនៃក្រសួង ស្ថាប័នពាក់ព័ន្ធ ព្រមទាំងសាមីខ្លួនដូចមានចែងក្នុងមាត្រា២ថ្មី ត្រូវទទួលអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ ២០០៦

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច និងឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៤
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ